រាជបណ្ឌិត្យសភាកម្ពុជា

# «វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១»

## ភាគទី៧ - វគ្គទី១

អត្ថបទចងក្រងដោយៈ លោកស្រី ស៊ីន ច័ន្ទអមរា
មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា



ពិធីសម្ពោធវិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១ ក្រោមអធិបតីភាព ព្រះបាទសម្ដេចស៊ីសុវត្ថិ និងរេស៊ីដង់ជាន់ខ្ពស់បារាំង[1]

[1]រូបភាព (https://sopheak.wordpress.com/2015/11/30)។

## ៧-ខ្លឹមសារនៃសុន្ទរកថាទាំង៤ក្នុងពិធីសម្ពោធ

សូមរំឭកថា ពិធីសម្ពោធវិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១ បានប្រព្រឹត្តទៅនៅក្រុងភ្នំពេញ រយៈពេល៣ថ្ងៃ គឺពីថ្ងៃសុក្រទី២៧ ខែកុម្ភៈ ដល់ថ្ងៃអាទិត្យទី១ ខែមីនា ឆ្នាំ១៩២៥។ នៅក្នុងកម្មវិធីថ្ងៃសុក្រទី២៧ ខែកុម្ភៈ មានពិធីជប់លៀងជូនអតីតយុទ្ធជនចាប់ពីម៉ោង៨យប់ និងពិធីរាំកម្សាន្តនៅក្នុងសាលបុណ្យនៃសាលាក្រុងភ្នំពេញ ចាប់ពីម៉ោង១០:៣០នាទីយប់។ នៅក្នុងកម្មវិធីថ្ងៃសៅរ៍ទី២៨ ខែកុម្ភៈ មានក្បួនដង្ហែកងទ័ពចាប់ពីម៉ោង៧ព្រឹក និងការសម្ពោធ «ផ្ទាំងរំឭក»(Plaque commémorative) អំពីការស្នាក់នៅក្នុងសាលាក្រុងភ្នំពេញនៃលោកសេនាប្រមុខ សុព (Maréchal Joffre) កាលពីខែធ្នូ ឆ្នាំ១៩២១។ កម្មវិធីថ្ងៃអាទិត្យទី១ ខែមីនា ឆ្នាំ១៩២៥ គឺពិធីសម្ពោធវិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១។

ភាគទី៧ វគ្គទី១នេះ នឹងបង្ហាញអំពីខ្លឹមសារដើម (ដោយមានការកែសម្រួលមួយចំនួន) ដែលមាននៅក្នុងបណ្ណសារស្ដីពី«បុន្យ៍ឆ្លងវិមានដែរសាងក្នុងក្រុងកម្ពុជាធិប្តី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ ដល់ឆ្នាំ១៩១៨)»[2] ជាបន្តដូចតទៅ៖

នៅពេលព្រឹកថ្ងៃអាទិត្យទី១ ខែមីនា (ឆ្នាំ១៩២៥) បណ្ដាជនដោយសាសន៍ៗ ហើយនឹងសេនាទាហាននោះ ត្រូវនៅតាមកន្លែងដែលគេរៀបចំទុកជាស្រេច។ លុះដល់ម៉ោង៧កន្លះគត់ គឺពេលដែលបានសម្រេចក្នុងប្រូក្រាម(កម្មវិធី)នោះ លោកឡឺរេស៊ីដង់ សុប៉េរីយើរ(រេស៊ីដង់ជាន់ខ្ពស់) បានជិះឡានមកដល់ជាមួយនឹងព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ។ ពេលមកដល់ក្រោមវិមាននោះ ជាងចម្លាក់ឈ្មោះឌូក្វាំង(Ducoing) លោកឡឺរេស៊ីដង់ មែរ[3] និងលោកអាំងស្ប៉ិកទារការប៉ូលីទីក[4] ក៏បានទទួលលោកឡឺរេស៊ីដង់ សុប៉េរីយើរ និងព្រះករុណា។ នៅវេលានោះត្រែក៏ផ្លុំឡើង ហើយភ្លេងបារាំងរបស់ក្រុមយុទ្ធនា អុងស៊ីយាម កូឡូនីញ៉ាល់[5] និងភ្លេងព្រះករុណា ក៏រួមគ្នាផ្លុំបទម៉ាសីយែស(Marseillaise)[6]។ មានបណ្ដាជនស្រុកអាយគ្រប់សាសន៍ មានអ្នកតូចអ្នកធំសព្វគ្រប់ មកពីគ្រប់ទិសតំបន់នគរស្រុកខ្មែរ មកនៅសម្ងំស្ងាត់

---

[2] បុន្យ៍ឆ្លងវិមានដែរសាងក្នុងក្រុងកម្ពុជាធិប្តី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ ដល់ឆ្នាំ១៩១៨), នៅក្នុងរាជកិច្ចរាជការ ឆ្នាំ១៩២៥, ទំព័រ៧៩-៨២។

[3] លោកឡឺរេស៊ីដង់មែរ(Monsieur le Résident-Maire) គឺលោកចៅហ្វាយក្រុង(ភ្នំពេញ)។

[4] អាំងស្ប៉ិកទារក្រសួងប៉ូលីទិក (Inspecteur politique) គឺអធិការខាងនយោបាយ។

[5] ក្រុមយុទ្ធនា«អុងស៊ីយាមកូឡូនីញ៉ាល់» (Onzième Coloniale) គឺទាហានអាណានិគម អង្គភាពទី១១។

[6] គឺបទភ្លេងជាតិបារាំង ("La Marseillaise" is the national anthem of France. The song was written in 1792 by Claude Joseph Rouget de Lisle in Strasbourg after the declaration of war by France against Austria)។

ស្មៀម ចាំតែមើលគេយកសំពត់គ្របវិមាននោះចេញ។ លើទីរោងទាំង២ដែលសង់នៅក្នុងទីសួននៅជុំវិញវិមាន ហើយដែលនៅចំមុខវិមាននោះ បារាំងក្នុងក្រុងភ្នំពេញទាំងអស់ក៏មកជ្រៀតគ្នាមើល។

ពិតមែនតែមានបណ្ដាជនជាច្រើនអនេក តែគ្មានបណ្ដាលឱ្យកើតហេតុអ្វីឡើយ គ្មានលាន់ឮអ្វីសោះ ស្ងាត់នេះសឹងតែឮសួររុយហើក្នុងវេលានោះ ទើបលោកប៉ាទ្រី ដែលជំនួសឱ្យក្រុមកុំមីតេ(គណៈកម្មាធិការ)ដែលត្រូវចាត់ចែងឱ្យសាងវិមាននោះ បានប្រកាសប្រគល់វិមានជូនទៅរាជការអាណាព្យាបាល។ លោកឡឺរេស៊ីដង់ មែរ ក្រុងភ្នំពេញ តាំងអធិប្បាយដោយសំឡេងខ្លាំង សរសើរអំពីកិច្ចការយ៉ាងល្អរបស់លោកឱ្យក្វាំងរួចហើយ ទើបអធិប្បាយថាបណ្ដាជនខ្មែរនៅទីក្រុងក្ដី នៅស្រុកស្រែក្ដី មានចិត្តសោមនស្សមកសងគុណឱ្យបុគ្គលដែលស្លាប់ទៅ ហើយលោកឡឺរេស៊ីដង់ មែរ ទាយទុកថាតាំងពីថ្ងៃនេះទៅ មុខជាបណ្ដាជន នឹងរាប់អានតម្កល់តម្កើងវិមាននេះជាប្រាកដ។ ឯសេចក្ដីអធិប្បាយរបស់ចាងហ្វាងរាជការក្រុមមឿង (សាលាក្រុង)នោះ ដូចមានសព្វគ្រប់ខាងក្រោយនេះ។

### ៧-១-សុន្ទរកថារបស់ចាងហ្វាងរាជការក្រុមមឿង

សូមក្រាបបង្គំទូលទ្រង់ព្រះករុណា និងជម្រាបលោក ឡឺរេស៊ីដង់ សុប៉េរីយើរ សូមទ្រង់ សូមបានជ្រាប។

ត្បិត៣ឆ្នាំមកហើយ មានក្រុមកុំមីតេ[7]១ ទទួលរៀបចំចាត់ចែងឱ្យធ្វើវិមានសម្រាប់រំឭកគុណដល់អ្នកដែលទទួលអនិច្ចកម្មក្នុងចម្បាំងធំ។ គណៈកម្មាធិការក៏បានទទួលកិច្ចធុរៈដែលបន្ទុកលើខ្លួនរៀងមក។ ឥឡូវពេលនេះហើយដែលគណៈកម្មាធិការ នឹងប្រគល់វិមាននេះឱ្យបណ្ដាជនរំពែកយកគន់បាន ហើយក្រុងភ្នំពេញសោត ក៏នឹងអួតខ្លួនបានដោយមានរបស់មានតម្លៃនេះ។ រស្មីព្រះអាទិត្យដែលរះឡើងព្រឹកនេះ ក្នុងក្រុងភ្នំពេញនោះឃើញថា អ្នកទាំងអស់គ្នានឹងបានសេចក្ដីក្សេមក្សាន្តទៅថ្ងៃក្រោយ ហើយក្នុងនគរទាំងប៉ុន្មានដែលឡើងប្រទេសអាំងដូស៊ីន[8]នោះ មានតែនគរខ្មែរ១ជាដំបូង ដែលបានធ្វើប្រដាប់សម្រាប់គោរពដល់ពួកកូនចៅ ដែលបាត់បង់ជីវិតដោយមានថ្វីដៃដូច្នេះ។

អាណាប្រជានុរាស្ត្រទាំងមូលក្នុងក្រុងកម្ពុជា ក៏បានចេញទ្រព្យសងបំណុលផែនទឹកផែនដី តាមធនធានតិចច្រើននៃខ្លួន។

---

[7] ក្រុមកុំមីតេ (Comité) ប្រែថាគណៈកម្មាធិការ។

[8] ដែលឡើងប្រទេសអាំងដូស៊ីន(Indochine) មានន័យថាដែលនៅក្រោមការគ្រប់គ្រងរបស់«សហភាពឥណ្ឌូចិន» ក្រោមការគ្រប់គ្រងរបស់បារាំង (ដែលមានរដ្ឋ៥គឺ កូសាំងស៊ីន កម្ពុជា អណ្ណាម តុងកឹង និងឡាវ)។

នៅក្រុងភ្នំពេញដែលបណ្ដារាស្ត្រមានទ្រព្យសម្បត្តិគ្រាន់បើនោះ ក៏បានចេញក្រាស់ក្រែល តាមសេចក្ដីសទ្ធារបស់ខ្លួន។ នៅទីប្រជុំស្រុកក្រៅ[9] រហូតទៅស្រុកស្រែចម្ការ ដែលបណ្ដារាស្ត្រខំធ្វើការនឹងកម្លាំងខ្លួន ហើយសង្ឃឹមតែផលប្រយោជន៍ដែលធ្វើបានពីព្រះធរណីនិងរបស់ដែលធ្វើនឹងដៃនោះ អ្នកទាំងអស់គ្នាក៏បានចេញប្រាក់តាមធនធានខ្លួន ដើម្បីនឹងធ្វើបុណ្យរំឭកដល់បងប្អូនញាតិសាលោហិត ដែលស្លាប់ក្នុងកិច្ចធុរៈរបស់ខ្លួន។ ឯការឃោសនាប្រាក់នេះ កាលនុះមិនបាច់ចាំបង្ខំ ឬនិយាយទទូចនោះទេ គឺអ្នកទាំងអស់គ្នាបានចេញធនធានដោយសប្បាយរីករាយ ព្រោះបានយល់ពីការដ៏ធំសំខាន់ដែលរាជការបានគិតធ្វើនោះ។ ឯបណ្ដារាស្ត្រទាំងអស់ក៏ឃើញថាស្មោះត្រង់នឹងការនេះ។ ចំណែកខាងជាងដែលសាងវិមាននេះសោត ក៏បានខិតខំធ្វើវិមាននេះ មានស្នាដៃអស់ពីចិត្ត។ ឯសំពត់(ក្រណាត់)ដែលគ្របវិមាន កុំឱ្យអ្នកទាំងពួងមើលឃើញនោះ ក៏នឹងបកយកចេញ។

បើបកសំពត់ចេញដូច្នេះហើយ ក៏នឹងឃើញក្រុមសេនា ទាហានបារាំងសែសម្នាក់ ខ្មែរម្នាក់ ដែលរួបរួមគ្នាធ្វើបុណ្យ អំពីការមានជ័យជម្នះដោយយកឈាមទៅតស៊ូជាមួយគ្នា។ នៅគ្រឿងជាន់ពីក្រោមធ្វើពីសំរិទ្ធិដែលមានក្បាច់ក្បូតាមបែបរចនាខេមរៈនោះ មានរូបពួកខ្មែរ ដែលជាអ្នកសម្មាទានរក្សាសីល លុះឃើញក្រុមសេនាទាហានត្រឡប់មកវិញក៏មានចិត្តស្រឡាញ់រំជួល ហើយយកគ្រឿងបូជាទៅជូនដល់អ្នកដែលមានជ័យជម្នះ។ ឯក្នុងរូបទាំងប៉ុន្មាននោះឃើញមានឫកកិរិយាយ៉ាងល្អបំផុត ទ្រង់ទ្រាយក៏សមសួនព្រមទាំងសេចក្ដីរុងរឿង។ អាណាប្រជានុរាស្ត្រសោតក៏មានសេចក្ដីរាប់អានគោរពប្រណិបត្តិ ដល់អ្នកដែលជួយស្រោចស្រង់ខ្លួន។ ការរចនាក៏ជាល្អសំខាន់ សេចក្ដីទាំងអស់នេះនឹងនាំឱ្យបណ្ដាជនដែលពិនិត្យវិមាននេះមានសេចក្ដីអាសូររំជួលក្នុងចិត្តជាខ្លាំង។ ក៏ប៉ុន្តែជាជាងសំដីដែលនឹងហើរបាត់ទៅ ជាជាងពាក្យដែលនឹងយកមករៀបរាប់ពុំបាននោះ អាណាប្រជានុរាស្ត្រនឹងពិនិត្យមើលវិមាននេះ ចំពោះនៅភ្នែកខ្លួនតែម្ដង។

ឥឡូវនេះតាងនាមគណៈកម្មាធិការ ដែលទូលព្រះបង្គំ ដែលខ្ញុំបានអធិបតីនោះ ក្នុងខណៈនេះទូលព្រះបង្គំនិងខ្ញុំសូមប្រគល់ថ្វាយទ្រង់ព្រះករុណានិងជូនលោក នូវវិមានដែលកសាងសម្រាប់រំឭកគុណដល់អ្នកមានថ្វីដៃ ជាកូនស្រុកនគរបារាំងសែសដែលមកស្នាក់អាស្រ័យក្នុងស្រុកខ្មែរ(គឺបារាំងដែលមកនៅស្រុកខ្មែរ) និងអ្នកស្រុកអាយដែលធ្វើការជូនស្រុកកំណើតបន្ទាប់របស់ខ្លួន(គឺខ្មែរដែលទៅជួយច្បាំងបារាំង) គឺអ្នកទាំងអស់នេះហើយ ដែលបានយកជីវិតខ្លួនទៅប្ដូរជួសនគរបារាំងសែសឱ្យមានជ័យជម្នះបានរៀបរយត្រឹមត្រូវនឹងផ្លូវច្បាប់ ព្រមទាំងសេចក្ដីឯកចិត្រក្នុងជំពូទ្វីប។

---

[9] ទីប្រជុំស្រុកក្រៅ គឺទីប្រជុំជននៅតាមខេត្ត។

ដល់មុងស៊ីយ៉ើរ( ប៉ាទ្រី )ថ្លែងសុន្ទរកថាចប់នោះ គេទះដៃជាច្រើន ហើយទើបតាំងបើកយកសំពត់ដែលគ្របវិមាននោះចេញ វិមាននោះក៏លេចឡើងពេញល្អនៅមុខបណ្ដាជនដែលមានសេចក្ដីស្រើបស្រាលហើយដែលលាន់មាត់សរសើរជាយូរ។

( សូមរង់ចាំអានភាគបន្ត... )